ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Aug-2012, 11:43
CMS/CFO: Sann Rada

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ
ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១២

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

## សេចក្តីបន្ថែមខ្លីចំពោះសំណើអនុលោមតាមវិធាន ៣៥ សុំ ឲ្យមានចំណាត់ការជាបន្ទាន់ ប្រឆាំងនឹងរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
Joshua ROSENSWEIG

ផ្ញើជូន៖

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី**

PICH Ang
Elisabeth SIMONNEAU-FORT

## I. សេចក្តីផ្តើម

១. អនុលោមទៅតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង (វិធាន)[1] មេធាវីការពារជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") តទៅនេះសូមដាក់សេចក្តីបន្ថែមខ្លីចំពោះសំណើអនុលោមតាមវិធាន ៣៥ សុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងលោក **ហោ ណាំហុង** រដ្ឋមន្ត្រីការបរទេសរបស់កម្ពុជា ("សំណើ") ដែលដាក់នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២[2] ។

## II. អង្គហេតុពាក់ព័ន្ធ

២. បន្ថែមពីលើអង្គហេតុដែលមានចែងនៅក្នុងសំណើ[3] ព្រឹត្តិការណ៍ខាងក្រោម និងជាពិសេស*ព្រឹត្តិការណ៍ដែលកើតឡើងជាបន្តបន្ទាប់* គឺពាក់ព័ន្ធយ៉ាងសំខាន់ទៅនឹងសំណួរថា តើរដ្ឋមន្ត្រីការបរទេសបច្ចុប្បន្ននៃរាជរដ្ឋាភិបាលកម្ពុជា នាពេលថ្មីៗនេះបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលនៅ អ.វ.ត.ក. ដែរ ឬអត់។

ក. ដូចដែលបានកត់សម្គាល់នៅក្នុងសំណើ នៅពេលប្រឈមនឹងសំណួររបស់មេធាវីការពារក្តីនៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ សាក្សី **ភី ភួន** (ហៅ ចៀម អតីតប្រធានសន្តិសុខនៅក្រសួងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជាអតីតអភិបាលរងស្រុកម៉ាឡៃ) បានបញ្ជាក់ថានៅក្នុងមួយកំឡុងពេល រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ **ហោ ណាំហុង** "គ្រប់គ្រងជំរុំអប់រំបឹងត្របែក"[4]។

ខ. សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ **ហោ ណាំហុង** ("សេចក្តីថ្លែងការណ៍") ដែលបានបដិសេធនូវតួនាទីគ្រប់គ្រងនៅបឹងត្របែក និងបានអះអាងថា ជាការមិនត្រឹមត្រូវសម្រាប់

---

[1] សូមមើលវិធានផ្ទៃក្នុង អ.វ.ត.ក. (វិសោធនកម្មលើកទី៨) ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ ។

[2] ឯកសារលេខ E-219 ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២,ERN 00834491–00834500 ។

[3] សូមមើលសំណើ នៅកថាខណ្ឌ២ ដល់កថាខណ្ឌ៥ ។

[4] សូមមើលឯកសារ E-1/99.1 ប្រតិចារិតសវនាការថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ (សវនាការលើកទី៨៧), ERN 00831888–00831999, ទំព័រ 63:1–4 (សំណួរ: អរគុណលោកសាក្សី។ ថាតើធ្លាប់លោក ហោ ណាំហុង ធ្វើជាប្រធាន ឬអនុប្រធានបឹងត្របែក ដែរ ឬទេ? ចម្លើយ: នៅពេលតំណាងក្រសួងទៅទទួលគាត់ គាត់គ្រប់គ្រងនៅទីនោះ) ។

អ.វ.ត.ក. ក្នុងការ "បង្កភាពចម្រូងចម្រាស់" បានចេញផ្សាយនៅថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០១២ និងបានចុះផ្សាយទាំងក្នុងកាសែត *ឌឹ ខេមបូឌា ដេលី, ភ្នំពេញប៉ុស្តិ៍* និងសារព័ត៌មានភាសាខ្មែរជាច្រើនទៀតនៅថ្ងៃបន្ទាប់[5]។

គ. បួនថ្ងៃក្រោយមក គឺនៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១២ គេហទំព័រ Cambodia Express News បានរាយការណ៍ថា លោក **វង្សមតុន** ហៅ **ភី ភួន** បានអះអាងថាបានឆ្លើយដាក់ ហោ ណាំហុង នៅ អ.វ.ត.ក. ដោយច្រឡំដោយសារតែការសួរសំណួរច្រំដែលមានលក្ខណៈធ្វើឱ្យភ័ន្តច្រឡំពីសំណាក់សហមេធាវីបរទេសរបស់ជនជាប់ចោទ[6]។ អត្ថបទសារព័ត៌មាននេះបានកត់សម្គាល់ថា លោក **ភី ភួន** "មានអារម្មណ៍ថាគាត់ត្រូវបានគេបង្ខំឱ្យផ្តល់សក្ខីកម្មចំពោះបញ្ហាអ្វីដែលគាត់មិនដឹង[7]។ ទាក់ទងនឹងការផ្លាស់ប្តូរគំនិតភ្លាមៗរបស់គាត់ លោក **ភី ភួន** បានប្រាប់ *កាសែត ឌឹ ខេមបូឌា ដេលី* ថាគាត់នឹងមិនព្រមត្រឡប់ទៅកាន់តុលាការវិញទេ ប្រសិនជាគាត់ត្រូវបានស្នើសុំឱ្យបញ្ជាក់ពីសក្ខីកម្មរបស់គាត់ លុះត្រាតែរដ្ឋាភិបាលចង់ឱ្យគាត់ទៅ។ "ខ្ញុំនឹងមិនទៅទេពីព្រោះខ្ញុំមិនស្រួលខ្លួន [...] ខ្ញុំមិនចង់ទៅទេ *ប៉ុន្តែប្រសិនបើរដ្ឋាភិបាលត្រូវការខ្ញុំ ខ្ញុំនឹងទៅ*"[8]។

សេចក្តីថ្លែងការណ៍នេះហាក់ដូចជាធ្វើបានសម្រេចយ៉ាងមានប្រសិទ្ធិភាព និងគ្រប់គ្រាន់នូវលទ្ធផលដែលគេចង់បាន ។

---

[5] សូមមើលសំណើនៅកថាខណ្ឌទី២ ។ សូមមើលផងដែរ Chhorn Chansy និង Wallace, "សាក្សីនៅសាលាក្តីខ្មែរក្រហមបដិសេធការអះអាងរបស់ ហោ ណាំហុង" *កាសែត ឌឹ ខេមបូឌា ដេលី* ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ ("អត្ថបទកាសែត ឌឹ ខេមបូឌា ដេលី") ទំព័រ១៧ (បន្ទាប់ពីរបាយការណ៍សារព័ត៌មានអំពីសក្ខីកម្មនេះត្រូវបានចុះផ្សាយលោក ហោ ណាំហុង បានចេញសេចក្តីថ្លែងការណ៍ខឹងសម្បារមួយ ដោយស្តីបន្ទោសធ្ងន់ៗដល់មេធាវីការពារក្តីថា "បានបង្ករឱ្យមានភាពចម្រូងចម្រាសក្នុងចំណោមសាធារណៈជន") ។

[6] អត្ថបទ Bayon "សាក្សីអះអាងក្នុងសវនាការថា Vân គឺជាប្រធានមន្ទីរកែប្រែបឹងត្របែក" *Cambodia Express New,* ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១២ ( អត្ថបទ Bayon)។ សូមមើលផងដែរ អត្ថបទ *កាសែត ឌឹ ខេមបូឌា ដេលី* នៅទំព័រ១៧ ។

[7] អត្ថបទ Bayon ។

[8] អត្ថបទ *កាសែត ឌឹ ខេមបូឌា ដេលី* នៅទំព័រ១៧*(គូសបញ្ជាក់បន្ថែម)* ។

## III. ច្បាប់ពាក់ព័ន្ធ

៣. មេធាវីការពារសូមដាក់សារណាផ្នែកច្បាប់ដែលមានចែងនៅក្នុងកថាខណ្ឌទី៦ រហូតដល់កថាខណ្ឌទី ១០ នៃសំណើ ។

## IV. អំណះអំណាង

៤. ក្រៅពីចរិតលក្ខណៈខុសច្បាប់របស់សេចក្តីថ្លែងការណ៍ ដែលជាការថ្លែងជាសាធារណៈដោយមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងបញ្ហាដែលកំពុងតែពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង[9] ពេលនេះវាកាន់តែច្បាស់ទៀតថាការរំលោភមាត្រា ៣៥ បានលេចចេញជារូបរាងឡើង: **ហោ ណាំហុង** ពិតជាបាន "គំរាមកំហែង បំភិតបំភ័យ[...] ឬបើមិនដូច្នេះទេ ជ្រៀតជ្រែក*សាក្សី* [...] ដែល [...] បាន [...] *ផ្តល់ភស្តុតាង*នៅចំពោះ [...] អង្គជំនុំជម្រះ[10]។ ជាពិសេស ផ្អែកលើអង្គហេតុដែលបានគូសបញ្ជាក់ខាងលើ វាទំនងថាសាក្សី **ភី ភួន** បានបដិសេធជាសាធារណៈនូវ*សក្ខីកម្មផ្ទាល់មាត់*នៅក្នុងករណី០០២[11] (និងដោយមានភាពពាក់ព័ន្ធគឺសេចក្តីថ្លែងការណ៍របស់គាត់កាលពីឆ្នាំ ២០០០ទៅកាន់សារព័ត៌មាន[12]) *ពីព្រោះតែ*សំពាធពីរដ្ឋមន្ត្រីការទេសតាមរយៈការចេញផ្សាយសេចក្តីថ្លែងការណ៍[13]។

---

[9] សូមមើលសំណើ នៅកថាខណ្ឌទី១២-២១ ។

[10] វិធាន ៣៥(១)(ឃ)(បញ្ជាក់បន្ថែម) ។

[11] សូមមើលកថាខណ្ឌ២(ខ) ខាងលើ ។

[12] មានការចុះផ្សាយនៅក្នុងអត្ថបទសារព័ត៌មានមួយនាខែ កក្កដា ឆ្នាំ ២០០០ ថា "ចៀម ក្រោយមកស្គាល់ជា ភី ភួន" អតីតបុគ្គលិកក្រសួងការបទេស" និងជាអភិបាលរងស្រុកម៉ាឡៃ" បាននិយាយទៅកាន់ *កាសែត ឌឹ ខែមបូឌា ដេលី* ដូចតទៅ: អនុលោមតាមផែនការរបស់[ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ]...យើងចង់បាន ហោ ណាំហុង មកធ្វើជាបុគ្គលិក។ យើងមិនដឹងឲ្យស៊ីជម្រៅអំពីជំហររបស់គាត់ទេ ដូច្នេះយើងត្រូវធ្វើការជាមួយគាត់ និងធ្វើតេស្តភាពស្មោះត្រង់របស់គាត់ថា តើគាត់ជឿជាក់មកលើកម្ពុជាប្រជាធិបតេយ្យដែរ ឬអត់។ *ដូច្នេះយើងតែងតាំងគាត់ឲ្យធ្វើជាប្រធានបឹងត្របែក*"។ Kelly McEvers & Thet Sambath "មេដឹកនាំរដ្ឋាភិបាល និងខ្មែរក្រហម: ប្រវត្តិសាស្ត្រខ្មោងងងឹត", *កាសែត ឌឹ ខែមបូឌា ដេលី* ចេញផ្សាយនៅថ្ងៃទី១-២ ខែកក្កដា ឆ្នាំ២០០០ នៅទំព័រ ១១-១២ (បញ្ជាក់បន្ថែម)។ កំណត់សំគាល់: បើទោះបីមានភាពខុសគ្នាបន្តិចបន្តួចនៅក្នុងការសរសេរឈ្មោះខ្មែរ ក៏ច្បាស់ណាស់បុគ្គលដែលយោងនៅក្នុងអត្ថបទនេះ គឺជាសាក្សី ភី ភួន ដែរ។

៥. ម្យ៉ាងទៀត ដូចដែលបានគូសបញ្ជាក់នៅក្នុងសំណើ ពាក្យស្នើសុំតាមវិធាន៣៥ អាចទទួលយកបានជោគជ័យ ដោយមិនត្រូវការការបង្ហាញ [...] ដែលថាអំពើចង់ឲ្យជះឥទ្ធិពលលើចរិតលក្ខណៈរបស់សក្ខីរបស់សាក្សី ចេញជាលទ្ធផលឡើយ[14]។ ប៉ុន្តែ ក្នុងករណីមានភស្តុតាងដែលថា ការប្រព្រឹត្តល្មើស (នៅទីនេះ គឺសេចក្តីថ្លែងការណ៍) សម្រេចបានលទ្ធផល (នៅទីនេះ គឺការបដិសេធរបស់សាក្សី **ភី ភួន**) អង្គហេតុបែបនេះ (i)គាំទ្រដល់ការយល់ឃើញដោយអង្គជំនុំជម្រះសាលាដំបូងថា មានហេតុផល "ឲ្យជឿជាក់បាន" ថាបុគ្គលម្នាក់ប្រហែលជាបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ និង(ii) ជះឥទ្ធិពលលើជំហានត្រឹមត្រូវដែលត្រូវចាត់ការ។ ហេតុដូច្នេះ បើមានការជ្រៀតជ្រែតដោយជោគជ័យនោះតម្រូវឲ្យចាត់ការយ៉ាងធ្ងន់ធ្ងរជាងការជ្រៀតជ្រែកមួយដែលមិនមានអានុភាព។

៦. ដំណោះស្រាយដែលស្នើនៅក្នុងសំណើ (និងនៅក្នុងសេចក្តីបន្ថែមនេះ) មិនកំហិតត្រឹមតែការវាយតម្លៃលើការប៉ះពាល់របស់សេចក្តីថ្លែងការណ៍ទៅលើសាក្សី **ភី ភួន** នោះទេ។ តែកិច្ចប្រឹងប្រែងរបស់មេធាវីការពារក្តីទាក់ទងនឹងបញ្ហានេះ គឺមានលក្ខណៈទូលំទូលាយជាង សំដៅប្រឆាំងទៅនឹងអានុភាពរបស់សេចក្តីថ្លែងការណ៍នេះទៅលើសាក្សីដទៃទៀត ដែលនឹងចូលខ្លួនផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២។ ដោយសារចំណាប់អារម្មណ៍យ៉ាងធ្ងន់ធ្ងរនៅក្នុងសំណើដែលលើកឡើងបានរំកិលពីបញ្ហាទូទៅជា បញ្ហាជាក់លាក់ អង្គជំនុំជម្រះគប្បីចាត់វិធានការឲ្យបានឆាប់រហ័ស ដើម្បីទប់ស្កាត់ការខូចខាត បន្ថែមទៀត។

## V. សេចក្តីសន្និដ្ឋាន

៧. បន្ថែមពីលើដំណោះស្រាយជាក់លាក់ដែលបានស្នើឡើងនៅក្នុងសំណើ[15] និងពិចារណាពីទំងន់នៃភស្តុតាងថ្មីដែលបានដាក់នៅក្នុងសំណើនេះ អង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ៣៥(២)(ខ)

---

[13] កំណត់សម្គាល់: ដោយពុំទាន់មានការបញ្ជាក់ច្បាស់ចំពោះបញ្ហាដែលលើកឡើងដោយមេធាវីការពារក្តី ការកត់សម្គាល់ជាសាធារណៈរបស់សាក្សី ភី ភួន ដែលថា គាត់នឹងចូលមកអវតក ជាលើកទៅពីរ "បើសិនជារដ្ឋាភិបាលត្រូវការគាត់" បន្តផ្តល់ការសង្ស័យដោយសមហេតុផលថាការបដិសេធ គឺកើតចេញពីសេចក្តីថ្លែងការណ៍នោះ។

[14] សូមមើលសំណើ នៅកថាខណ្ឌ១០ (ស្រង់យុត្តិសាស្ត្រនៅ អ.វ.ត.ក) ។

[15] សូមមើលសំណើ នៅកថាខណ្ឌ២៣ ។

គប្បីធ្វើការស៊ើបអង្កេតបន្ថែមដើម្បីស្វែងរកថា  តើមានមូលហេតុគ្រប់គ្រាន់សម្រាប់ធ្វើការស៊ើបអង្កេតប្រឆាំង **ហោ ណាំហុង** ដែរ ឬទេ។

**សហមេធាវីការពារក្ដីលោក នួន ជា**

Michiel PESTMAN    Jasper PAUW    Andrew IANUZZI